ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២២

នៅក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៧លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់

២-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៤

៣-ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤ ជំនួសលោកជំទាវ **ឱ សុខុម** ដែលបានទទួលមរណភាព

៤-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា នីតិកាលទី៤

៥-ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន០១រូប ជំនួសសមាជិក ដែលបានទទួលមរណភាព

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់

- បានផ្តល់សេវាជូនសមាជិកគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោតស្តីពី ផែនការឆ្ពោះទៅការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញជួបសវនាការការងារជាមួយគណៈប្រតិភូក្រសួង ស្ថាប័ននានា រួមមានៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍, ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ខេត្តកោះកុង, អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ, អនុប្រធានទី១ អាជ្ញាធរអគ្គិសនីកម្ពុជា និងពុទ្ធសាសនបណ្ឌិត្យ នៅរាជធានីភ្នំពេញ ដើម្បីឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ និងព័ត៌មាន ពិនិត្យតាមច្រកទ្វារព្រំដែនអន្តរជាតិ និងសម្រង់ព័ត៌មាន ពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពត ខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មដើម្បីតាមដានការអនុវត្តការងារតាមវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ព្រមទាំងជួបសំណេះ-សំណាលការងារជាមួយគណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ស្មៀន មេភូមិ និងនាយប៉ុស្តិ៍នគរបាល នៅខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមប្រជុំអន្តរក្រសួង ស្តីពី វឌ្ឍនភាពនៃការពិនិត្យសិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផលជាក់ស្តែងក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ នៅក្នុងភូមិសាស្ត្រខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ក្រោមអធិបតីភាពឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមជាគណៈអធិបតី និងជាកិត្តិយសក្នុងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន៩២លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការសុខាភិបាល ស្តីពី វិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអំពាវនាវឱ្យប្រជាពលរដ្ឋទៅចាក់វ៉ាក់សាំងទាំងដូសមូលដ្ឋាន និងដូសជំរុញឱ្យបានគ្រប់ៗគ្នា និងបានបំពេញភារកិច្ចផ្សេងៗទៀតនៅមូលដ្ឋាន រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន២,៣១២លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈអភិបាលខណ្ឌ ឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាល ដើម្បីស្តាប់ពីស្ថានភាពការងារសន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងដំណើរការការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន៧៩លើក

- បានរៀបចំ និងផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារទីចាត់ការចំនួន០១ខ្នង អគារសិក្សាថ្មីចំនួន០១ខ្នង និងអគាររដ្ឋបាលវិទ្យាល័យសម្តេច ជា ស៊ីម ជ្រោយចង្វារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចុះធ្វើការងារសង្គមកិច្ចជួយប្រជាពលរដ្ឋ នៅសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារចំនួន១២លើក

- បានទទួលពាក្យបណ្តឹងចំនួន៣៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៣២ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន២៣ករណី កំពុងពិនិត្យសិក្សាចំនួន១០ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន២២ករណី និងបានទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០៦ករណី និងតម្កល់ទុកមិនចាត់ការចំនួន០២ករណី ដោះស្រាយបញ្ចប់ចំនួន០១ករណី ធ្វើលិខិតរំលឹកជំរុញការដោះស្រាយ

ពាក្យបណ្ដឹងចំនួន០១ករណី និងទទួលឯកសារពាក្យបណ្ដឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន២៨ករណី

- បានរៀបចំកម្មវិធីធ្វើបទបង្ហាញ កិច្ចប្រជុំ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភាចំនួន១៩លើក

- បានធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប និងវិទ្យាស្ថានវ៉ាន់ដា ព្រមទាំងសិក្ខាកាមវគ្គបណ្ដុះបណ្ដាលអន្តរជាតិ International Training Program ( ITP)ចំនួន៣៩៣នាក់

- បានផ្ដល់សេវាជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខេត្តកណ្ដាល ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង

- បាននាំយកថវិការបស់**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ចំនួន១០,០០០ដុល្លារសហរដ្ឋអាមេរិក និង២០លានរៀល ជូនកាកបាទក្រហមកម្ពុជា

- បាននាំយកថវិការបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ចំនួន២០លានរៀល ឧបត្ថម្ភជូនកាកបាទក្រហមកម្ពុជា ព្រមទាំងនាំយកថវិកាចំនួន១០លានរៀល ឧបត្ថម្ភដល់សាលាបឋមសិក្សាអនុវត្តរាជធានី ដើម្បីកែលម្អបរិស្ថានសាលារៀន

- បាននាំយកថវិការបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឧបត្ថម្ភដល់សមាគមចលនាវប្បធម៌ដើម្បីកុមារកំព្រា កុមារក្រីក្រចំនួន៤លានរៀល

- លេខាធិការដ្ឋានសមាគមសង្គហៈនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាននាំយកបច្ច័យចំនួន២លានរៀល ប្រគេនព្រះភិក្ខុ សច្ចកល្យាណោ **យន់ លីអេង** មានអាពាធបេះដូង គង់នៅវត្តទំពូងអង្គចំរើនមានជ័យ ខេត្តកំពង់ស្ពឺ

- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និងរៀបចំអំណោយចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

- បានផ្ដល់សៀវភៅដែលបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជូនក្រសួងការពារជាតិ និងកងរាជអាវុធហត្ថការពារព្រំដែនកម្ពុជា-ឡាវចំនួន៥,២១៥ក្បាល

- បានរៀបចំសារលិខិតថ្វាយព្រះពរ ជូនពរ និងថ្លែងអំណរគុណរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ទូលថ្វាយ**ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា, សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ,**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និងឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន៧៨លិខិត

- បានរៀបចំ និងផ្ញើសាររំលែកទុក្ខក្នុងនាមថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២លិខិត និងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធ ព្រមទាំងពិធីបញ្ចុះសពរបស់ឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន០៩លើក

- បានបោះពុម្ពសៀវភៅស្តីពី សកម្មភាពការងាររបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ទទួលជួបភ្ញៀវអន្តរជាតិ (ឆ្នាំ២០១២-២០២១)ចំនួន១០០ក្បាល

- បានផលិតប័ណ្ណរថយន្តចេញ-ចូលព្រឹទ្ធសភាឆ្នាំ២០២៣ចំនួន៣,៤០០សន្លឹក

- បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ ចំនួន ២,៨០០ក្បាល។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជូនសារតាំង ជំនួបសម្តែងការគួរសម សវនាការ និងជម្រាបលាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ និងអង្គទូតនានាចំនួន១៦លើក

- បានរៀបចំចាត់ចែងជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការដើម្បីពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងអង្គការនីតិប្បញ្ញត្តិទាំងពីរ ព្រមទាំងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រពៃរវាងប្រជាជន និងប្រទេសទាំងពីរកម្ពុជា-កូរ៉េ នៅសាធារណរដ្ឋកូរ៉េ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម សវនាការ និងពិភាក្សាការងារជូនសមាជិក សមាជិកាព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានាចំនួន១៤លើក

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់ រួមមាន៖ កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយមហាសន្និបាតសភាតំបន់អាស៊ី(APA) ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងបញ្ហាផ្សេងៗ, កិច្ចប្រជុំសភាតំបន់អាស៊ី (APA) ក្រោមប្រធានបទ "វេទិកាសភាស្តីពីការស្រាវជ្រាវ និងសហប្រតិបត្តិការកិច្ចការបណ្ណាល័យ", កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃក្រុមសភាជាតិ(APF), កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង, កិច្ចប្រជុំគណៈកម្មការសភា (APF), កិច្ចប្រជុំក្រុមទទួលបន្ទុកការសើរើលក្ខន្តិកៈ(APF), កិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក(ASGP), មហាសន្និបាតសហភាព

អន្តរសភាលើកទី១៤៤(IPU-144), កិច្ចប្រជុំត្រៀមរៀបចំមហាសន្និបាតអាយប៉ា លើកទី៤៣ ដែលកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះ, កិច្ចប្រជុំប្រចាំឆ្នាំរបស់(AIPACODD) លើកទី៥ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ាស្តីពី គ្រឿងញៀន, កិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមអ្នកនយោបាយអាយប៉ា លើកទី១៣ ក្រោមប្រធានបទ "ការអនុវត្តលើសេចក្តីសម្រេចនៃមហាសន្និបាតអាយប៉ា លើកទី៤២ និងកិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ចឌីជីថល ក្នុងអាស៊ានក្រោយវិបត្តិកូវីដ-១៩" និងសិក្ខាសាលាស្តីពីពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០២២ ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្មជូនដល់សមាជិកសភាពិភពលោក ដោយមានការសហការរៀបចំជាមួយ Temasek Foundation និងអគ្គលេខាធិការដ្ឋាននៃអង្គការពាណិជ្ជកម្មពិភពលោក(WTO)

- ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យភ្ញៀវជាតិ និងអន្តរជាតិនានាចូលជួបសម្តែងការគួរសម និងជម្រាបលាចំនួន០៧លើក និងបានចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយអគ្គលេខាធិការព្រឹទ្ធសភាបារាំងស្តីពី សហប្រតិបត្តិការបណ្តុះបណ្តាលធនធានមនុស្ស និងពិធីចុះអនុស្សរណៈជាមួយវិទ្យាស្ថានស្រាវជ្រាវច្បាប់នៃសាកលវិទ្យាល័យ Zurich ស្តីពី ជំនាញស្រាវជ្រាវច្បាប់ និងបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង(APF) និងដៃគូនានា នៅសាធារណរដ្ឋបារាំង ព្រមទាំងអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអេចិន្ត្រៃយ៍សមាគមអគ្គលេខាធិការសភាពិភពលោក(ASGPF) នៅប្រទេសសេណេហ្គាល់

- ឯកឧត្តម **លីម ប៊ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយទីប្រឹក្សា និងលេខាទី១ នៃស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

- បានរៀបចំពិធីប្រគល់ និងទទួលជំនួយសម្ភារវេជ្ជសាស្ត្រពីអង្គការចែករំលែកសង្គ្រោះអាយុជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ព្រមទាំងបានរៀបចំពិធីប្រគល់ឱសថ និងបរិក្ខារពេទ្យជូនដល់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យគន្ធបុប្ផា(ភ្នំពេញ) និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា

- បានរៀបចំកម្មវិធីផ្សព្វផ្សាយសៀវភៅដែលផ្តល់ដោយមជ្ឈមណ្ឌលវប្បធម៌ចិន និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន នៅសាលសិក្ខាសាលាខាងត្បូង ព្រឹទ្ធសភា

- បានរៀបចំជូន កញ្ញា **គង់ សុមនី** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលគ្រឿងឥស្សរិយយសពីស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតបារាំង, ស្ថានទូតកូរ៉េ, ស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្ដីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, អង្គការតម្លាភាពកម្ពុជា(TI Cambodia), មូលនិធិ Gong Xiang, សាលាភូមិន្ទរដ្ឋបាល, សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ, មជ្ឈមណ្ឌលសភាអាស៊ី (PCA), មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), វិទ្យាស្ថានSalaCyber, វិទ្យាស្ថាន DataU Academy, វិទ្យាស្ថានCamKPI Professional Academy, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), ភ្នាក់ងារសន្តិសុខព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនHUAWEI, ក្រុមហ៊ុន Cambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្ដុះបណ្ដាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩(ដូសជំរុញ) ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ, ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមទាំងក្រុមគ្រួសារ ប្រកបដោយជោគជ័យ

- បានធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ ព្រឹទ្ធសភា នីតិកាលទី៤

- បានទទួលសម្ភារឧបករណ៍បច្ចេកទេសព័ត៌មានវិទ្យា ជំហានទី១ ក្រោមការឧបត្ថម្ភគាំទ្ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានសហការជាមួយរដ្ឋសភា និងកម្មវិធីនុយមេរិច នៃសភាប្រើភាសាបារាំង (APF) រៀបចំសិក្ខាសាលាស្ដីពី ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងសេរីភាពសារព័ត៌មាន បញ្ហាប្រឈម និងដំណោះស្រាយ នៅវិមានព្រឹទ្ធសភា

- បានជួបពិភាក្សាការងារជាមួយក្រុមហ៊ុន Huawei ដើម្បីស្នើសុំការគាំទ្រលើគម្រោងដូចខាងក្រោម៖

+ការរៀបចំបន្ទប់រៀន E-Learning សម្រាប់នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

+ទស្សនកិច្ចសិក្សាឈ្វេងយល់ពីការរៀបចំបន្ទប់ E-learning នៅអគារធ្វើការរបស់

ក្រុមហ៊ុន Huawei

+រៀបចំកម្មវិធីបាឋកថា/បទបង្ហាញរៀងរាល់សប្តាហ៍លើប្រធានបទនានា ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាក៏ដូចការវិវត្តន៍នានា ក្នុងសង្គមបច្ចុប្បន្ន

- បានប្រជុំពិនិត្យ និងពិភាក្សាស្តីពី កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានប្រជុំស្តីពី ការងារគ្រប់គ្រងបុគ្គលិកនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រជុំពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្នុង

- បានប្រជុំពិនិត្យលើសេចក្តីព្រាងកម្មវិធីផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០២២

- បានប្រជុំពិនិត្យផែនការមេស្តីពី បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិច (ឆ្នាំ២០២២-២០៣០)

- បានប្រជុំពិនិត្យ និងកែសម្រួលវីដេអូចំនួន០២ខ្សែ ស្តីពីសមិទ្ធផលនានា ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិនដល់ព្រឹទ្ធសភាកម្ពុជា និងស្តីពីបណ្ណាល័យព្រឹទ្ធសភា

- បានប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងស្តីពី ទម្រង់ទិន្នន័យសមាជិកព្រឹទ្ធសភានីតិកាលនីមួយៗ និងការទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋមកកាន់ព្រឹទ្ធសភា តាមប្រព័ន្ធឌីជីថល

- បានប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំពិធីប្រកាសឯកឧត្តម **លឹម ប៊ុនហុក** ជាអគ្គលេខាធិការរងព្រឹទ្ធសភាថ្មី

- បានរៀបចំពិធីជួបសំណេះសំណាលការងារជាមួយសន្តិសុខផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

## ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានទទួលលិខិតចូលចំនួន៣,៥២៧ច្បាប់ និងបញ្ជូនលិខិតចេញចំនួន២,១៩២ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺគ្រុនចាញ់ មកបាញ់ថ្នាំសម្លាប់សត្វមូស និងសត្វល្អិតក្នុងបរិវេណព្រឹទ្ធសភា

- បានរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងការបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆមាសទី១ ឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានរៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៣-២០២៥) និងគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា

- បានបើកប្រាក់បៀវត្សប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានដេញថ្លៃការផ្គត់ផ្គង់ការបោះពុម្ព ប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារអនាម័យ និងឯកសណ្ឋានមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៣៨៥ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន៨៤ប័ណ្ណ

- បានរៀបចំបញ្ជីរាយនាមមន្ត្រីរាជការដែលត្រូវបានវាយតម្លៃតម្លើងថ្នាក់បៀវត្សតាមវេនជ្រើសរើស និងវេនអតីតភាពសម្រាប់ឆ្នាំ២០២២

- បានធ្វើជំរឿនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២២

- បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន២២វគ្គ មានសិក្ខាកាមចូលរួមចំនួន៣៩៨នាក់ និងក្រៅប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន០៣នាក់ ព្រមទាំងសិក្ខាសាលាក្នុងប្រទេសចំនួន០៧លើក មានសិក្ខាកាមចូលរួមចំនួន២២០នាក់

- បានទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យនានាចំនួន៣១កន្លែង

- បានផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់បណ្ឌិត អនុបណ្ឌិត និងថ្នាក់បរិញ្ញាបត្រ ជូនដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចុះបំពេញទស្សនកិច្ចសិក្សានៅក្រុមហ៊ុន HUAWEI រាជធានីភ្នំពេញ

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើចំនួន២៩លើក ព្រមទាំងបានដាំផ្កានានា និងដើមឫស្សីក្នុងបរិវេណព្រឹទ្ធសភាចំនួន១,៣២៩គុម្ព/ដើម

- បានជួសជុល និងតុបតែងលម្អស្រះចិញ្ចឹមត្រីក្នុងបរិវេណអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានទទួលរថយន្តប្រើប្រាស់ថាមពលអគ្គិសនីចំនួន០២គ្រឿង សម្រាប់គាំពារបរិស្ថាន

- បានរៀបចំផ្ទេរខុទ្ទកាល័យអគ្គលេខាធិការរង អគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈទៅកាន់ទីតាំងថ្មី

- បានជួសជុលកែលម្អ និងបំពាក់សម្ភារៈ អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា, អគារអតីតនាយកដ្ឋានព័ត៌មានវិទ្យា, អគារអតីតខុទ្ទកាល័យអគ្គលេខាធិការរង, ខុទ្ទកាល័យអគ្គលេខាធិការរងថ្មី និងជំនួយការ, ស្ពាបខាងកើត និងខាងលិចផ្នែកខាងក្រោមអគារក្រហម, បន្ទប់សារព័ត៌មានក្រោមអគារក្រហម, នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ, អគារអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ, បន្ទប់កាមេរ៉ាសុវត្ថិភាពរបស់អង្គភាពសន្តិសុខ, បន្ទប់ទឹកសាលខាងជើង និងនៅអគារគណៈកម្មការទី១០, សាលអាននៅបណ្ណាល័យ, ការរៀបចំបន្ទប់គ្រូពេទ្យ និងបំពាក់សម្ភារ បរិក្ខារសម្រាប់ថែទាំសុខភាពជូនសមាជិកព្រឹទ្ធសភា, ការរៀបចំកន្លែងធ្វើការ និងប្រព័ន្ធអគ្គិសនីជូនក្រុមសិក្សាស្រាវជ្រាវទូទៅ, ការរៀបថ្មភ្នំនៅជុំវិញអគារសាលប្រជុំពេញអង្គ, ការពង្រីកផ្នែកខាងក្រោយសាលបណ្ណាល័យព្រឹទ្ធសភា និងកែលម្អរោងឥត្រជំនៅសួនម៉ាឡេស៊ី ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា

- បានជួសជុលប្រព័ន្ធអគ្គិសនី សម្អាតដំបូលតាមអគារ និងសាលប្រជុំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានជួសជុលប្តូរគ្រោងទ្វារនៅអគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាទាំង៣, បានធ្វើធ្នើរដែកដាក់សម្ភារនៅបន្ទប់Studio ក្រោមអគារក្រហម

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យដំណើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១,៣៥៣គ្រឿង/លើក

- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន១៧៨លើក

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមករា ដល់ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ ទូលថ្វាយ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ដល់ខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

- បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់នាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១ និងទី២ ឆ្នាំ២០២២។

**៥.២-ការងារសេវាច្បាប់៖**

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន១,៦៨៥ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន៣៤ច្បាប់

- បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និង នីតិកាលនីមួយៗ

- បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (ឆ្នាំ២០២២-២០២៤)។

**៥.៣-ការងារស្រាវជ្រាវ៖**

-បានសិក្សាស្រាវជ្រាវ និងផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់

-បានកសាងឯកសារស្រាវជ្រាវ តាមដានការងារកំណែទម្រង់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាលក្នុងអំឡុងពេលកូវីដ-១៩ ចំនួន០៤អត្ថបទ

-បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា (ឆ្នាំ២០២១-២០៣៥)ចំនួន០៤អត្ថបទ

-បានស្រាវជ្រាវ និងផលិតឯកសារផ្សេងៗពាក់ព័ន្ធនឹងច្បាប់ សេដ្ឋកិច្ច សង្គម និងថវិកាចំនួន ០៧ប្រធានបទ

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៤២៣អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ ចំនួន២៤ច្បាប់។

**៥.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន១០លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ

Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន៥៦២គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន ៧៧៧ប្រធានបទ

- បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៨០គ្រឿង

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន៨៨៥ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្នី និងសងសៀវភៅចំនួន២៩៧ក្បាល

- បានផលិត និងផ្សព្វផ្សាយវីដេអូសមិទ្ធផលរបស់ព្រឹទ្ធសភាចំនួន០២ខ្សែ

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន២៧៧លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១២២លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ៨,៩៩២ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

**៥.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៧១លើក

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន៦២ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមករា ដល់ខែមិថុនា

ឆ្នាំ២០២២ ចំនួន០៦ច្បាប់

- បានកសាងជំនួយស្មារតី សុន្ទរកថា និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន ៧៩ច្បាប់

**៥.៦-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ ចំនួន១១៤លើក

- បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារនៃអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន២៤២លើក ប្រចាំសប្តាហ៍ចំនួន២៤លើក និងប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២

- បានធ្វើរបាយការណ៍ស្តីពី ការស្រាវជ្រាវត្រួតពិនិត្យអំពីការអនុវត្តការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមករា ដល់ខែមិថុនា ឆ្នាំ២០២២។

**៥.៧-ការងារត្រួតពិនិត្យ ៖**

- លទ្ធផលនៃការអនុវត្តការងាររបស់អគ្គនាយកដ្ឋានទាំង៥ ប្រចាំឆមាសទី១ ឆ្នាំ២០២២ នេះសម្រេចបាន៖ ១.មុខងារនីតិកម្មទទួលបាន១០០%, ២.មុខងារតាមដានការអនុវត្តច្បាប់ទទួលបាន៦០%, ៣.មុខងារតំណាងទទួលបាន៥៥%, ៤.មុខងារសហប្រតិបត្តិការអន្តរជាតិទទួលបាន៨០% និង៥.មុខងារអភិវឌ្ឍស្ថាប័នទទួលបាន៨២%។ ដូច្នេះលទ្ធផលនៃការអនុវត្តមុខងារទាំង៥ របស់អគ្គនាយកដ្ឋានទាំង៥ គិតជាមធ្យមសម្រេចបាន៧៥% នៃផែនការប្រតិបត្តិប្រចាំឆមាសទី១

ឆ្នាំ២០២២។

❖ សូចនាករប្រៀបធៀបលទ្ធផលតាមមុខងារនីមួយៗ

| សូចនាករ ឆមាសទី១ ឆ្នាំ២០២១ | សូចនាករ ឆមាសទី១ ឆ្នាំ២០២២ |
|---|---|
| មុខងារនីតិកម្ម ១០០% | មុខងារនីតិកម្ម ១០០% |
| មុខងារតាមដានការអនុវត្តច្បាប់ ៤២% | មុខងារតាមដានការអនុវត្តច្បាប់ ៦០% |
| មុខងារតំណាង ៤៧% | មុខងារតំណាង ៥៥% |
| មុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ៥២% | មុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ៨០% |
| មុខងារអភិវឌ្ឍន៍ស្ថាប័ន ៦៨% | មុខងារអភិវឌ្ឍន៍ស្ថាប័ន ៨២% |




- ការអនុវត្តគោលនយោបាយ បានទាន់ពេលវេលាសម្រាប់មន្ត្រីរាជការចុះបេសកកម្មក្នុងប្រទេសចំនួន២៣៨នាក់ ធ្វើការលើសម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៩១៩នាក់ លំហែមាតុភាពចំនួន០៨នាក់ រៀបអាពាហ៍ពិពាហ៍ចំនួន០៦នាក់ សុំប្រាក់វិភាជន៍គ្រួសារចំនួន២៧នាក់ សុំប្រាក់ឧបត្ថម្ភប្រពន្ធចំនួន០៣នាក់ និងប្រាក់ឧបត្ថម្ភកូនចំនួន២៦នាក់ មន្ត្រីរាជការចូលនិវត្តន៍ចំនួន០៤នាក់។ ចំពោះការងារមូលនិធិសង្គមកិច្ច បានឧបត្ថម្ភដល់មន្ត្រី និងបុគ្គលិកជាប់កិច្ចសន្យាមានជំងឺកូវីដ-១៩ ទទួលមរណភាព និងគ្រោះថ្នាក់ផ្សេងៗសរុបចំនួន៧៩នាក់។ ជារួមការអនុវត្តគោលនយោបាយនានា រក្សាបាននូវតម្លាភាព គណនេយ្យភាព ផ្តល់ផលប្រយោជន៍ និងលើកទឹកចិត្តដល់មន្ត្រីរាជការ។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១,៤០០ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ និងចងបដា ពាក្យស្លោកចំនួន៨០លើក

- បានតុបតែងលម្អ និងរៀបចំពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧៨ច្បាប់ ស្មើនឹង១,០០៨នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១៨ច្បាប់ ស្មើនឹង១៨នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២,៨២០លើក

- បានដោះស្រាយថវិកា សម្រាប់រៀបចំដង្វាយថ្វាយ**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៦៤សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១១៩លើក មានអ្នកចូលរួមចំនួន៣,២៦៩នាក់

- បានសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ ជួបគ្រោះថ្នាក់ចរាចរណ៍ លំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន១,៥០២លីត្រ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន២៣,៨៩១ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៧២៧ក្បាល អស់ក្រដាសចំនួន១៩៧,៦៩៨សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១,០០០លើក ស្មើនឹង២,១០៥នាក់ ព្រមទាំងបានជួសជុលរថយន្ត ប្តូរប្រេងម៉ាស៊ីន ប្តូរសំបកកង់រថយន្ត ប្តូរអាគុយ និងធៀករថយន្តចំនួន២៩គ្រឿង

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន៨៥លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន១,៤៣៦លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១១៤លើក។

**III-ទិសដៅការងារឆមាសទី២ ឆ្នាំ២០២២**

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ ជំងឺកូវីដ-១៩ ជំងឺពកត្បាតថ្មី គ្រោះធម្មជាតិ

+បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

+ទ្រទ្រង់ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិកព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល

+បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

- ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។

## ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៣- មុខងារតំណាង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋឥណ្ឌា

-ត្រៀមរៀបចំជូនគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាតលើកទី៤៧ នៃសភាប្រើភាសាបារាំង នៅប្រទេសរ៉ាន់ដា

-ត្រៀមចូលរួមមហាសន្និបាត (APF), (IPU), (AIPA) និង(APPF) ព្រមទាំងកិច្ចប្រជុំពាក់ព័ន្ធ

-ត្រៀមចូលរួមកិច្ចប្រជុំ (ASGPF) និងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ MAROC

-ត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ឡើងវិញជាមួយដៃគូសំខាន់ៗរបស់មជ្ឈមណ្ឌលសភាអាស៊ី(PCA) លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ និងរដ្ឋសភាបារាំង)

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត (PCA, AVI) និងដៃគូផ្សេងៗទៀត

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, AIPA, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការត្រៀមការពារគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ ក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយ

-ការត្រៀមរបាយការណ៍ទូទាត់ថវិកាសម្រាប់ឆមាសទី១ ឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងការអនុវត្តថវិកាសម្រាប់ឆមាសទី២ ឆ្នាំ២០២២

-ការត្រៀមបែងចែកកញ្ចប់ថវិកាព្រឹទ្ធសភាឆ្នាំ២០២៣ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ការត្រៀមរបាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តតាមដាន និងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងស្នើកសាងអគារថ្មី២ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ និងការស្នើសុំឥណទានបន្ថែមពីរាជរដ្ឋាភិបាល

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ឆមាសទី២ ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-ការត្រៀមរៀបចំបែបបទដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៣

-បន្តវិចារណកម្មថវិកា៖ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់

នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងប្លាស្ទិក)

-កែលម្អបរិស្ថាន និងអនុវត្តការងារជួសជុលផ្សេងៗក្នុងករណីចាំបាច់ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងវិន័យការងារ

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត (ឥណ្ឌា...)

-ត្រៀមរៀបចំពិធីស្តីពី ការជួយឧបត្ថម្ភគាំទ្ររបស់ស្ថានទូតចិនប្រចាំកម្ពុជា ក្នុងការជួសជុលអគារក្រហម និងរៀបចំបណ្ណាល័យអេឡិចត្រូនិច

-បន្តរៀបចំផលិតវីដេអូស្តីពី បណ្ណាល័យព្រឹទ្ធសភា និងវីដេអូសមិទ្ធផលនានា ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន

-រៀបចំសៀវភៅទិនានុលេខន៍ព្រឹទ្ធសភាឆ្នាំ២០២៣

-ត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី នវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ សវនកម្មផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ

-ត្រៀមបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវគ្គបណ្តុះបណ្តាលកិច្ចការសភា នៅសាលារដ្ឋបាលជាតិបារាំង, វគ្គសូចនាករ សមិទ្ធកម្មគន្លិះ(KPI) នៅប្រទេសឥណ្ឌា និងវគ្គកិច្ចការសភា នៅប្រទេសកាណាដា

-ត្រៀមធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣។

IV-**សេចក្ដីសន្និដ្ឋាន**

ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តការងារលើមុខងារទាំង៩ សម្រេចបានលទ្ធផលល្អប្រសើរជាងឆមាសទី១ ឆ្នាំ២០២១។ លទ្ធផលទាំងនេះផ្ដើមចេញពីភាពជន់ និងភាពឈ្លាសវៃ ព្រមទាំងការចេះបត់បែនរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គនាយកដ្ឋាន នាយកដ្ឋាន ក្នុងការប្រតិបត្តិការការងាររបស់ខ្លួនស្របតាមបរិបទនៃការបើកឱ្យដំណើរការឡើងវិញលើគ្រប់វិស័យរបស់ប្រទេសជាតិ។ សកម្មភាពលេចធ្លោគឺការយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋានក្នុងរយៈពេលវិស្សមកាល ចាប់ពីថ្ងៃទី០៣ ខែឧសភា ដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ តាមរយៈការចុះប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ជាពិសេសណែនាំប្រជាពលរដ្ឋឱ្យទៅចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសជំរុញ)ឱ្យបានគ្រប់ៗគ្នា និងក្ដាប់នូវស្ថានការណ៍ជាក់ស្ដែង ពិនិត្យតាមដានយន្តការនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អំពីបញ្ហាប្រឈម និងសំណូមពរនានា ព្រមទាំងការចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិពាក់កណ្ដាលឆ្នាំ២០២២ ទទួលបានលទ្ធផលល្អតាមរយៈការអនុវត្តការទូតសភាដ៏ទន់ភ្លន់ជាសក្ដានុពលថ្មីបន្ថែមទៀត ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីមានលក្ខណៈទាក់ទាញជាងមុន។ ដើម្បីឱ្យស្របតាមបរិបទនៃការវិវត្តថ្មី ជាពិសេសការកាត់បន្ថយថវិកាសម្រាប់ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ខិតខំពង្រឹងប្រសិទ្ធភាពចំណាយ ដោយអនុវត្តគោលការណ៍ 3E's ដើម្បីធានានិរន្តរភាព និងប្រក្រតីភាពការអនុវត្តថវិកាឆ្នាំ២០២២រហូតដល់បំណាច់ឆ្នាំ ដោយផ្ដោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធាន និងការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងល្អប្រសើរ។

ថ្ងៃសុក្រ ១០ កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**